**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌

លេខ : ៤៥ កយ.សសរ.២២

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារចំពោះកិច្ចរបស់ក្រសួងយុត្តិធម៌ប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម កេងប្រវ័ញ្ចពលកម្ម និងអាជីវកម្មផ្លូវភេទ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១ .-**

បង្កើតក្រុមការងារចំពោះកិច្ចរបស់ក្រសួងយុត្តិធម៌ប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម កេងប្រវ័ញ្ចពលកម្ម និងអាជីវកម្មផ្លូវភេទ ដែលមានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **កេត សុម៉ារិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ប្រធាន |
| ២-ឯកឧត្តម | **ម៉ែន ពេជ្រសាលី** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣-ឯកឧត្តម លោកជំទាវ | | ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត | សមាជិក |
| ៤-លោក | **នុប សុធនវិសុទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ | សមាជិក |
| ៥-លោកស្រី | **សុន សុខាលីដា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ | សមាជិក |
| ៦-លោកស្រី | **សុខ វិសាល** | ប្រធាននាយកដ្ឋានកិច្ចការអយ្យការ | សមាជិក |
| ៧-លោកស្រី | **ម៉ែន ផល្លីកា** | ប្រធាននាយកដ្ឋានកិច្ចការយុត្តិធម៌ព្រហ្មទណ្ឌ និងនគរបាលយុត្តិធម៌ | សមាជិក |
| ៨-លោក | **សេង ពុទ្ធី** | ប្រធាននាយកដ្ឋានកិច្ចការច្បាប់ព្រហ្មទណ្ឌ | សមាជិក |
| ៩-លោកស្រី | **យុន ច័ន្ទសោភា** | ប្រធាននាយកដ្ឋានគ្រប់គ្រងវត្ថុតាង និងផលនៃបទល្មើស | សមាជិក |
| ១០-លោក | **លី សុផាណា** | ប្រធាននាយកដ្ឋានស្រាវជ្រាវ និងស៊ើបអង្កេត | សមាជិក |
| ១១-កញ្ញា | **សុខ ឆច័ន្ទ** | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| ១២-លោក | **ជុំ ធីឡេង** | | លេខាធិការ |
| ១៣-លោក | **ឌី រីដា** | | លេខាធិការ |
| ១៤-លោក | **អៀម សំណាង** | | លេខាធិការ |
| ១៥-លោកស្រី | **ជា ធីតា** | | លេខាធិការ |
| ១៦-លោក | **ម៉េង ចាន់រតនា** | | លេខាធិការ |
| ១៧-លោក | **ឌិន ប៊ុរិន** | | លេខាធិការ |
| ១៨-លោក | **ហាក់ សុខម៉េង** | | លេខាធិការ។ |

**ប្រការ២ .-**

ក្រុមការងារចំពោះកិច្ចនេះ គឺជាសេនាធិការរបស់ក្រសួងយុត្តិធម៌លើការងារពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលនីតិវិធីក្នុងការស៊ើបអង្កេត ស្រាវជ្រាវ និងត្រួតពិនិត្យជនបរទេសតាមបណ្តាគោលដៅសង្ស័យ ដើម្បីឈានទៅដល់ការឃាត់ខ្លួនជនល្មើស និងសង្គ្រោះជនរងគ្រោះបានទាន់ពេលវេលា
- ជំរុញ និងពង្រឹងការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ និងការផ្តន្ទាទោស ពីបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ឱ្យបានតឹងរ៉ឹងស្របតាមច្បាប់ និងនីតិវិធីជាធរមាន
- ប្រមូល ចងក្រង និងរៀបចំតារាងស្ថិតិទិន្នន័យ អំពីការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ និងការផ្តន្ទាទោស ពីបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ



៤

- ជំរុញការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ និងការផ្តន្ទាទោស ពីបទល្មើសសម្អាតប្រាក់ស្របតាមច្បាប់ និងនីតិវិធីប្រតិបត្តិស្តង់ដា (SOP) ជាធរមាន ដោយសហការជាមួយក្រុមការងាររបស់ក្រសួងយុត្តិធម៌ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ក្នុងករណីដែលក្រុមការងារពិនិត្យឃើញនូវតម្រុយនៃបទល្មើសសម្អាតប្រាក់ ដែលកើតចេញពីបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជាប្រចាំជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៣ ._**

អនុប្រធាន និងសមាជិកក្រុមការងារចំពោះកិច្ច ត្រូវចូលរួមកិច្ចប្រជុំ និងបំពេញការងារតាមការចាត់តាំងរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានអាចកោះប្រជុំ និង/ឬ ដឹកនាំកិច្ចប្រជុំជំនួសបានតាមការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ៤ ._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានគ្រប់អង្គភាពក្រោមឱវាទនៃក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២

រដ្ឋមន្ត្រី

កើត រិទ្ធ

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ